ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១៧៥ /២២ គ.ជ.ប.ជ

# របាយការណ៍ខែកក្កដា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែសីហា ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក។ ទន្ទឹមនឹងនោះ សភាពការណ៍សាកលលោក មានការវិវត្តន៍ប្រែប្រួលថ្មីៗ ប្លែកៗ គួរឲ្យកត់សម្គាល់ និងមិនអាចប៉ាន់ស្មានបាន ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបំប្លែងថ្មី។ វិបត្តិនៃផលប៉ះពាល់ដោយ ជំងឺកូវីដ-១៩ មិនទាន់បានបញ្ចប់ផង ក៏មានព្រឹត្តិការណ៍ដ៏អាក្រក់ជាច្រើនទៀតកើតឡើងជាបន្តបន្ទាប់ថែមទៀត ក្នុងឆ្នាំ២០២២ នេះ ដែលរួមទាំងការផ្ទុះសង្គ្រាមរវាងប្រទេសដែលនៅជិតខាងគ្នានៅក្នុងទ្វីបអឺរ៉ុប គឺរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលស្រួចស្រាលជាងពេលណាទាំងអស់ ក្រោមការគាំទ្រពីអាមេរិក និងសម្ព័ន្ធមិត្តនៅសហគមន៍អឺរ៉ុប ប្រឆាំងនឹងរុស្ស៊ី ដែលធ្វើឲ្យប្រទេសផ្គត់ផ្គង់ផលិតផល ប្រើប្រាស់ ម្ហូបអាហារ និងប្រេងឥន្ធនៈ ទាំងពីរនេះ បានកាត់ផ្តាច់ពីប្រព័ន្ធសេដ្ឋកិច្ចពិភពលោក។ រីឯ បរិស្ថាន និងអាកាសធាតុ ប្រែប្រួលខុសពីធម្មតា គួរឲ្យបារម្ភ និងប៉ះពាល់ដល់ការរស់នៅរបស់មនុស្សសត្វលើផែនដី ធ្វើឲ្យប្រទេសជាច្រើន រងនូវវិបត្តិសេដ្ឋកិច្ច និងសង្គមជាសាកល។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយ បង្កើតនូវបទល្មើសថ្មីៗ ព្រមជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ទាក់ទាញជនរងគ្រោះ ឲ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឲ្យមានផលប៉ះពាល់យ៉ាងធំធេង លើជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឲ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់

តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញក្នុងអំឡុងពេលដែលមានការរីតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី "**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ៣. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីបែបបទគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- ក្រសួង-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាបៈ
  - រៀបចំវេទិកាទិវាពិភពលោក ដើម្បីសុវត្ថិភាព និងសុខភាពការងារ ឆ្នាំ២០២២ ក្រោមប្រធានបទ "ធ្វើសកម្មភាពរួមគ្នាដើម្បីកសាងវប្បធម៌សុវត្ថិភាព និងសុខភាពការងារជាវិជ្ជមាន" មានអ្នកចូលរួមសរុប ៧០០នាក់ (ស្រី ៣៦៧នាក់)។
  - រៀបចំពិធីបើកយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅក្នុងវិស័យសិប្បកម្ម ផលិតផល និងកសិឧស្សាហកម្ម មានអ្នកចូលរួមសរុប ២៨៥នាក់ (ស្រី ១៧៨នាក់) នៅឃុំឃុនរាម ស្រុកបន្ទាយស្រី។
- អង្គការAPLE សហការជាមួយ គ.ខ.ប.ជ ខេត្តក្រចេះ ធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅវិទ្យាល័យសិលាវេទីគាតឈន់ស្រុកឆ្លូង មានសិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ ចូលរួមសរុបចំនួន ១២៩នាក់។

#### ១.២. ការអប់រំដោយផ្ទាល់

នៅក្នុងខែកក្កដា ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **១០.៤៥៥**លើក មានអ្នកចូលរួមសរុបចំនួន ៤០៨.២៤០នាក់ (ធៀបនឹងខែមិថុនា មានចំនួន **៣៧៣.៤៧៩**នាក់ គឺមានការកើនឡើងចំនួន ៣៤.៧៦១នាក់ ស្មើនឹង ៩,៣០% ក្នុងនោះស្ត្រីចំនួន ២១៤.៦៣១នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៧ | ២.៥៦៣ | ១.៣៣២ | ១៤៨ | ៣.២២២ | ១.២៣៥ |
| | **សរុប ក្រសួង ស្ថាប័ន** | **១៧លើក** | **២.៥៦៣នាក់** | **១.៣៣២នាក់** | **១៤៨លើក** | **៣.២២២នាក់** | **១.២៣៥នាក់** |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៧៤២ | ២៦.១៩៦ | ១៥.៥១១ | ៦៥២ | ៤៤.៦០៥ | ២៣.១២៧ |
| ៣ | ខេត្តបាត់ដំបង | ៩៣៦ | ៣៦.៨៩១ | ១៩.៧៦៦ | ៦៥៥ | ១៨.៨១៩ | ១០.១៨៦ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៥៣ | ១៩.៥៩២ | ១០.៦៧៧ | ១១៧ | ៤.៣៨១ | ១.៨៥៤ |
| ៥ | ខេត្តសៀមរាប | ២៣៣ | ១៤.៧៧៣ | ៨.៧៤៨ | ១៩ | ៣៤៣ | ១៤៦ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.១៦៦ | ៣០.៣៥២ | ១៥.៧១៣ | ៩០៤ | ១០.៩៣៥ | ៥.៨០០ |
| ៧ | ខេត្តកំពង់ចាម | ១៨.៧៦ | ៩៨.១៣៦ | ៥០.៤៩៨ | ១.០៩១ | ៣៦.៩៧៣ | ១៩.៦០៥ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩ | ខេត្តព្រះវិហារ | | | | | | |
| ១០ | ខេត្តស្វាយរៀង | ២៨១ | ៨.៨៨១ | ៥.០៩១ | ៣ | ៧៥៦ | ៣១៦ |
| ១១ | ខេត្តប៉ៃលិន | ៧៧ | ១.៣៩៧ | ៣៥៦ | ៣៦ | ១.៣៥០ | ៣៣៣ |
| ១២ | ខេត្តកោះកុង | ២ | ១០២ | ៧៤ | ៥០ | ១.១៥៣ | ១.០៨៦ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ៣ | ១.០២០ | ៧៦០ | | | |
| ១៥ | ខេត្តតាកែវ | ៣២២ | ១១.៤៤៦ | ៥.៨៩៤ | | | |
| ១៦ | ខេត្តក្រចេះ | ២៧ | ១.៩១២ | ១.០២៦ | | | |
| ១៧ | ខេត្តកែប | ២៨ | ៥.៣៩៥ | ២.២៣៤ | ៣៩ | ១.៧៩៤ | ៧០៨ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ៧ | ៣៨០ | | | | |
| ២១ | ខេត្តព្រៃវែង | ៣១៦ | ១៨.០៧៩ | ៨.៨២៦ | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៤ | ២.២៤៤ | ១.៣០៣ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១៩ | ៤៤៥ | ៣៣៧ | ១៣៦ | ២.៥៦៩ | ១.៣៦៨ |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ៩៦ | ១៥៣៦ | ៧២១ | | | |
| សរុប រាជធានី-ខេត្ត | | ៦៥.៨៨លើក | ២៧៨.៧៧៧នាក់ | ១៤៧.៥៣៥នាក់ | ៣.៧០២លើក | ១២៣.៦៧៨នាក់ | ៦៤.៥២៩នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ១០.៤៥៥ លើក | | ចំនួនមនុស្សសរុប ៤០៨.២៤០ នាក់ | | ចំនួនស្ត្រី ២១៤.៦៣១ នាក់ | |

## ១.៣. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប)៖ ធ្វើការផ្សព្វផ្សាយដល់សហគមន៍ បានចំនួន ១១លើក មានអ្នកចូលរួមសរុប ៧១២នាក់ (ស្រី ៣១០នាក់)។
- អង្គការសោម៉ារីតាន់ភឺស (ខេត្តបាត់ដំបង )៖ ធ្វើការផ្សព្វផ្សាយដល់សហគមន៍ បានចំនួន ០១លើក មានអ្នកចូលរួមសរុប ៦៤នាក់។

## ១.៤. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

| សកម្មភាព | លទ្ធផល |
|---|---|
| ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក ។ | អ្នកទស្សនាតាមហ្វេសប៊ុក ២.១៣៣នាក់ |
| ខេត្តសៀមរាប៖ មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ ៩០លើក<br>ខេត្តត្បូងឃ្មុំ៖ មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ ១៣៦លើក និងតាមទូរទស្សន៍ ០៦លើក<br>ខេត្តព្រៃវែង៖ មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ ៥០លើក | តាមវិទ្យុ ២៧៦លើក<br>តាមទូរទស្សន៍ ០៦លើក |
| សរុប៖ តាមវិទ្យុ ២៧៦លើក តាមទូរទស្សន៍ ០៦លើក អ្នកទស្សនាតាមហ្វេសប៊ុក ២.១៣៣នាក់ | |

### ១.៥. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- ខេត្តកំពង់ចាម៖
  - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងវិទ្យុ ក្រោមប្រធានបទ «**ការផ្សព្វផ្សាយពីនីតិវិធីដល់ប្រជាពលរដ្ឋ ចំពោះការរៀបការជាមួយជនបរទេស**» ចំនួនន ០២លើក។
  - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានចូលរួមជាវាគ្មិនក្នុងវិទ្យុ ក្រោមប្រធានបទ «**ការពង្រឹង និងពង្រីកមគ្គុទ្ទេសក៍សិក្សាសហគមន៍**» ចំនួន ០១លើក។

## ២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- អង្គការសាម៉ារីតាន់ភឹស (ខេត្តបន្ទាយមានជ័យ)៖ ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ពលករ ចំនួន ២.២៩០នាក់ (ស្រី៨២៩នាក់) កុមារ ៣៣៣នាក់ (កុមារី ១៥៩នាក់)។
- អង្គការសាម៉ារីតាន់ភឹស (ខេត្តបាត់ដំបង)៖ ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ពលករ ចំនួន ២៩៣នាក់។

## ៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

- ខេត្តសៀមរាប៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ចជនបរទេស បានចំនួន ០៨សហគ្រាស ពិនិត្យឃើញមានជនបរទេសចំនួន ៤៤នាក់ (ស្រី ១៩នាក់) ក្នុងនោះអ្នកមានប័ណ្ណនិងសៀវភៅការងារ ៤៣នាក់ (ស្រី ១៨នាក់) និងគ្មានប័ណ្ណ និងសៀវភៅការងារ ចំនួន ០១នាក់ (ស្រី)។

### ៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១៥៦.៣៨៣នាក់ (ស្រី ៦៩.១៣៥នាក់) អនីតិជន ១.៦៣៧នាក់ (ស្រី ៥៨៧នាក់)៖
  - ស្របច្បាប់ ចំនួន ១០៤.៨៥៧នាក់ (ស្រី ៤៧.៦៥៨នាក់) អនីតិជន ៣៨៩នាក់ (ស្រី ១៦២នាក់)
  - មិនស្របច្បាប់ចំនួន ៥០.៩៥១នាក់ (ស្រី ២១.២០៩នាក់ )អនីតិជន ១.១៤២នាក់ (ស្រី ៣៩៥នាក់)
  - ដាច់ការទាក់ទងចំនួន ៥៧៥នាក់ (ស្រី ២៦៨នាក់) អនីតិជន ១០៦នាក់ (ស្រី ៣០នាក់)។
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១០១.៩៩៤នាក់ (ស្រី ៤៥.១៤៩នាក់) អនីតិជន ៤៣៤នាក់ (ស្រី ១៥២នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋានគរបាលខេត្តចំនួន០២ បានធ្វើការបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន ០៥លើក មនុស្សចំនួន ២៣នាក់ (ស្រី ០៧នាក់) អនីតិជន ០៤នាក់ រួចបានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ ទៅក្រៅប្រទេសទៀត ក្នុងនោះមាន៖
  - **ខេត្តបន្ទាយមានជ័យ** ចំនួន ០៣លើក មនុស្សចំនួន ១៧នាក់ (ស្រី ០៤នាក់) អនីតិជន ០២នាក់។
  - **ខេត្តបាត់ដំបង** ចំនួន ០២លើក មនុស្សចំនួន ០៦នាក់ (ស្រី ០៣នាក់) អនីតិជន ០២នាក់។

### ៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលក្រចេះ តាកែវ កំពង់ធំ កែប កំពង់ចាម និងខេត្តសៀមរាប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម ដល់

ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន ២៨១គោលដៅ មនុស្សចំនួន ៨៧២នាក់ (ស្រី ៦៧២នាក់)។

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ កោះកុង និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ០៩លើក។

**៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ ចំនួន ១៦៤នាក់ (ស្រី ១៧នាក់) មាន ១៨សញ្ជាតិ ក្នុងនោះជនជាតិកូរ៉េខាងត្បូង ៥៧នាក់(ស្រី ០៧នាក់) ចិន ៣៥នាក់ អាមេរិក ៣៤នាក់(ស្រី ០៨នាក់) កាណាដា ០៧នាក់ បារាំង ០៦នាក់ ម៉ាឡេស៊ី ០៤នាក់ អង់គ្លេស ០៤នាក់ ជប៉ុន ០៤នាក់(ស្រី ០១នាក់) អូស្រ្តាលី ០៣នាក់ នូវែលសេឡង់ ០២នាក់ អូទ្រីស ០១នាក់ ហ្វាំងឡង់ ០១នាក់ និងឥណ្ឌា ០១នាក់ ថៃ ០១នាក់ អាល្លឺម៉ង់ ០១នាក់ ម៉ូឡូវ៉ា ០១នាក់(ស្រី) ហ្វីលីពីន ០១នាក់ ឥណ្ឌូនេស៊ី ០១នាក់។ និងវាយតំលៃបញ្ជូនឱ្យក្រុមការងារច្រកចេញចូលតែមួយបានចំនួន ១៨១នាក់។ បានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ រៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន ១១នាក់ (ស្រី ០៩នាក់)។

**៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

| អង្គភាព | សកម្មភាព |
|---|---|
| ខេត្តក្រចេះ | -ភូមិកុមារកម្ពុជា SOS មានកុមារចំនួន ៨៧នាក់ (ស្រី ៣៨នាក់)។<br>-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះអធិការកិច្ច ចំនួន ០១លើក។ |
| ខេត្តពោធិ៍សាត់ | មានមណ្ឌលកុមារកំព្រារដ្ឋ មានកុមារចំនួន ០៩នាក់ (ស្រី ០៦នាក់)។<br>មានមណ្ឌលកុមារកំព្រាអង្គការ ១២មណ្ឌល មានកុមារចំនួន ១៦៩នាក់ (ស្រី ៧៧នាក់)។ |
| ខេត្តកែប | មានមណ្ឌលកុមារ ០១មណ្ឌល មានកុមារចំនួន ៣៨នាក់ (ស្រី ១២នាក់)។ |
| ខេត្តកំពង់ចាម | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រ សហគ្រាស កន្លែងលាងឡាន និងកន្លែងកំសាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ ០ឆ្នាំដល់៣ឆ្នាំ តាមស្រុក ឃុំ ភូមិគោលដៅមួយចំនួន។ |

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

**១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៥ករណី(ធៀបនឹងខែ

មិថុនា មានចំនួន ០៨ករណី កើនឡើងចំនួន ០៧ករណី) ស្មើនឹង៨៧,៥% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៩នាក់ (ស្រី ០២នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ០២នាក់ និងជាជនជាតិចិន ០៣នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ២០នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១១នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០៨នាក់ (ប្រគល់ឱ្យគ្រួសារ ២០នាក់) ក្នុងនោះចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៤ករណី/០០ករណី (កើនឡើង ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៧នាក់ (ស្រី ០១នាក់) ជនសង្ស័យជាជនជាតិចិន ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ០៦នាក់ មានៈ អាយុ១៨ឆ្នាំឡើង ០៦នាក់ (ប្រគល់ឱ្យគ្រួសារ ០៦នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០១ | ០១ | ០១ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០៣ | ០២ | |
| -អំពើលក់ដូរមនុស្ស | ០១ | ០១ | ០៣ | ចិន៣ |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០១ | ០១ | |
| *សរុប* | *០៤ ករណី* | *០៦ នាក់* | *០៧ នាក់* | *០៣ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១១ករណី/០៨ករណី (កើនឡើង ០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១២នាក់ (ស្រី ០១នាក់) ជនសង្ស័យជាអនីតិជន ០២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៤នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១១នាក់ និងអាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០២នាក់ (ប្រគល់ឱ្យគ្រួសារ ១៤នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ស្ថានទម្រង់ទោសនៃសញ្ចារកម្ម | ០១ | ០៣ | ០២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១០ | ១១ | ១០<br>(អនី.២) |
| *សរុប* | *១១ ករណី* | *១៤ នាក់* | *១២ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ៤.៨៧៥នាក់(ស្ត្រី ២.១០២នាក់) កុមារ ៧១៨នាក់ (កុមារី ៣៥១នាក់)សកម្មភាពមានដូចជា៖

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ** បានទទួលចំនួន ៣៤នាក់ (ស្ត្រី ២៧នាក់) កុមារ ០៣នាក់ (កុមារី ០២នាក់) មកពីប្រទេសចិន ២៨នាក់ និងម៉ាឡេស៊ី ០៦នាក់ ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ២៧នាក់ ជួញដូរកម្លាំងពលកម្ម ០១នាក់ និងងាយរងគ្រោះ ០៦នាក់(កុមារ) បន្ទាប់ពីបានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។
- **មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពីប្រទេសថៃចំនួន ៤.៨៤១នាក់ (ស្ត្រី ២.០៧៥នាក់)កុមារ ៧១៥នាក់ (កុមារី ៣៤៩នាក់) បានសម្ភាសកំណត់អត្តសញ្ញាណរកឃើញមុខសញ្ញាជនរងគ្រោះ ជនងាយរងគ្រោះ និងកុមារមិនមានមនុស្សអមដំណើរមកជាមួយចំនួន ១៦នាក់ (ស្ត្រី ០៨នាក់) កុមារ ០៦នាក់ (កុមារី ០៣នាក់) ក្នុងនោះរកឃើញជាករណីជួញដូរកម្លាំងពលកម្ម ០៩នាក់ និងងាយរងគ្រោះ ០៧នាក់ និងផ្តល់ការស្នាក់នៅរយៈពេលខ្លី ក្នុងមណ្ឌលសំចតមុនពេលបញ្ជូនទៅទទួលសេវាស្នាក់នៅបន្ត នៅអង្គការដៃគូ ០៨នាក់ និងបញ្ជូនទៅសហគមន៍វិញ ០៨នាក់។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន ៥០នាក់(ស្រី ៤២នាក់) អនីតិជន ០២នាក់ មកពីប្រទេសចិន ៤១នាក់(ស្រី ៤០នាក់) អនីតិជន ០២នាក់ និងម៉ាឡេស៊ី ០៩នាក់ (ស្រី ០២នាក់)។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈទៅចិន ៣៩នាក់(ស្រី) អនីតិជន ០២នាក់ និងស្នាក់នៅដោយខុសច្បាប់ ១១នាក់ (ស្រី ០៣នាក់) ចិន ០២នាក់(ស្រី ០១នាក់) និងម៉ាឡេស៊ី ០៩នាក់ (ស្រី ០២នាក់)។
- **ខេត្តបន្ទាយមានជ័យ៖** ស្នងការនគរបាលខេត្ត ពលករចូលតាមច្រកអូរបីជាន់ ច្រកបឹងត្រកួន ច្រកចំបក់ និងច្រកអន្តរជាតិប៉ោតប៉ែត ចំនួន ៦៥លើក មនុស្សចំនួន ៤.៤៨០នាក់ (ស្រី ១.៩០១នាក់) អនីតិជន ៧០២នាក់។
- **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០៦លើក មនុស្សចំនួន ៣៧នាក់(ស្រី ១៣នាក់) អនីតិជន ០៨នាក់។
- **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាម ចំនួន ០១លើក មនុស្សចំនួន ០៥នាក់ (ស្រី ០២នាក់)។

## ២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ១៨០នាក់ (ស្ត្រី ៨៥នាក់ កុមារី ៩២នាក់) ក្នុងនោះបានមកពីមន្ទីរ ស.អ.យ រាជធានីភ្នំពេញ ២៣នាក់ មន្ទីរស.អ.យ ខេត្តស្វាយរៀង ០៥នាក់ មន្ទីរ ស.អ.យ ខេត្តតាកែវ ០៥នាក់ និងមន្ទីរស.អ.យ ខេត្តពោធិ៍សាត់ ០៣នាក់ និងអង្គការដៃគូ ១៤៤នាក់ ជាករណីជួញដូរផ្លូវភេទ ៥៤នាក់ រំលោភបំពានផ្លូវភេទ ៧០នាក់ រំលោភសេពសន្ថវៈ ២៣នាក់ កេងប្រវ័ញ្ចផ្លូវភេទ ០៥នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០៧នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ០៧នាក់ និងងាយរងគ្រោះ ១៤នាក់ (ស្ត្រី ០៦នាក់ កុមារី ០៨នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សហការជាមួយក្រុមហ៊ុនចំនួន៧ បានបើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ។ | ១០ | ២០១ | ១១២ |
| **ខេត្តសៀមរាប៖** | | | |
| - លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការជីវិតនៅកម្ពុជា (TLC) បានធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីវិធានការបង្វែរអនីតិជនទំនាស់នឹងច្បាប់ នៅស្រុកបន្ទាយស្រី ស្រុកវ៉ារិន និងស្រុកប្រាសាទបាគង។ | ០១ | ៥៧ | ១៥ |
| - លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សហការជាមួយអង្គការបន្ទាយស្រី បានធ្វើការបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកអង្គរធំ។ | ០១ | ២៦ | ១៥ |
| - ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការជីវិត នៃកម្ពុជា បើកវគ្គបណ្តុះបណ្តាល ស្តីពីវិធានការបង្វែរអនីតិជនទំនាស់នឹងច្បាប់។ | ០១ | ៤៥ | ០៥ |
| **ខេត្តកំពង់ឆ្នាំង៖** ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួងអង្គការហោកា បើកវគ្គបណ្តុះបណ្តាល ស្តីពីការជួញដូរមនុស្ស និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារកុមារ និងច្បាប់នានាពាក់ព័ន្ធនឹងប្រព័ន្ធកិច្ចការពារកុមារ ក្នុងប្រទេសនិងក្រៅប្រទេស។ | ០១ | ១០ | ០៦ |
| **សរុប** | **១៤ វគ្គ** | **៣៣៩ នាក់** | **១៥៣ នាក់** |

#### ២. សិក្ខាសាលា

- **ខេត្តកំពង់ចាម៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបើកសិក្ខាសាលាបំប៉ន ស្តីពីការពង្រឹងក្រុមប្រឹក្សាយុជន និងកុមារកម្ពុជា សម្រាប់គណៈកម្មាធិការប្រតិបត្តិ ចំនួន ០១លើក សិក្ខាកាមចូលរួមចំនួន ១២០នាក់ (ស្រី ៦០នាក់) នៅស្រុកចំការលើ និងស្រុកកោះសូទិន។

### ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

#### ១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

  លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖

  - ដឹកនាំកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ រវាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយអង្គការ RATANAK International ស្តីពី **"កិច្ចសហការ សម្រាប់ការអនុវត្តគម្រោងបង្ការទប់ស្កាត់ ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស"** មានការចូលរួមពីលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់

អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការទាំង៦ និងតំណាងអង្គការ RATANAK International សរុបចំនួន ២០នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។

- ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ ផ្លូវច្បាប់អន្តរជាតិពាក់ព័ន្ធនឹងករណីជួញដូរមនុស្សឆ្លងដែន នៅក្នុងតំបន់តំបន់អាស៊ាន ជាមួយUnited Nations Office on Drugs and Crime (UNODC) និងអង្គការអាស៊ាន- អូស្ត្រាលី (ASEAN-ACT) មានការចូលរួមពីមានការចូលពីលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការទាំង៦ និងតំណាងពីយូអិន (United Nations ) នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកកិច្ចប្រជុំពិភាក្សាអំពីកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ ដើម្បីអនុវត្តពាក់ព័ន្ធនឹងករណីជួញដូរមនុស្សនៅក្នុងតំបន់អាស៊ាន មានការចូលពីលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការទាំង៦ លោកស្រី Rebecca Miller អ្នកសម្របសម្រួលតំបន់ការជួញដូរមនុស្ស និងការរត់ពន្ធជនចំណាកស្រុក(UNODC) លោកស្រី Marika Mc Adam ទីប្រឹក្សាច្បាប់ និងគោលនយោបាយអន្តរជាតិ (ASEAN-ACT) និងក្រុមការងារពាក់ព័ន្ធមួយចំនួនទៀត សរុបចំនួន ១៥នាក់ (ស្រី ០៥ នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំ ស្តីស្តីពីការបែងចែកការងារកំណែឯកសារអប់រំផ្សព្វផ្សាយ និងការប្រព្រឹត្តទៅនៃវគ្គបណ្តុះបណ្តាល កំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស មានការចូលលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការទាំង៦ នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំពិភាក្សា ការត្រៀមរៀបចំកម្មវិធីអន្តរសាសនាលើកទី៦ ដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខនេះ សមាសភាពចូលរួមមានៈ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រសួងធម្មការ និងសាសនា ក្រសួងវប្បធម៌ ក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងសាសនាធំៗទាំងបួននៅកម្ពុជា និងអង្គការដៃគូពាក់ព័ន្ធសរុបចំនួន ៥៨នាក់ នៅសាលប្រជុំក្រសួងមហាផ្ទៃ។

**២. ការងារជំនួបពិភាក្សា**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនាយកដ្ឋាននៃក្រសួងស.អ.យ បានធ្វើការជួបពិភាក្សាជាមួយសមភាគថៃតាមការស្នើសុំ ដើម្បីពិភាក្សា និងចុះត្រួតពិនិត្យ កំណត់ព្រំប្រទល់ដី សម្រាប់សាងសង់មណ្ឌលសំចត និងស្តារនីតិសម្បទា ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នៅក្នុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**គ. ការងារសម្របសម្រួល**

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ២១លើក មានអ្នកចូលរួមសរុប ៣០០នាក់ (ស្រី ១៣៨នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ១៣លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ០៨លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។

- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

# V. ទិសដៅខែសីហា ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤.គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងារ របស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥.បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦.បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧.បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨.ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩.បន្តរៀបចំវិធានការ *"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"* (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១.បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២.ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងា រគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ២១លើក) មនុស្សចំនួន ៣០០នាក់ (ស្រី ១២៨នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាតុមូល ស្តីពីអនុសាសន៍សេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការសិទ្ធិកុមារ នៅសណ្ឋាគារភ្នំពេញ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាតុមូល ស្តីពីអនុសាសន៍សេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការសិទ្ធិកុមារ នៅសណ្ឋាគារភ្នំពេញ។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពជាតិសុខភាពជនទេសន្តប្រវេសន៍២០២២-២០៣០ នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៦ច្បាប់ លិខិតចូល ១៣ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៩ច្បាប់ លិខិតចូល ០៥ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកក្កដា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ប្រចាំខែកក្កដា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគី។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |

| | |
|---|---|
| | - គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គជ.ប.ជ។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៧៧ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន២១សកម្មភាព។<br>- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ០៩ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុម បានអញ្ជើញចូលរួមធ្វើជាអ្នកសម្របសម្រួល ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីគោលនយោបាយសុខភាពជនចំណាកស្រុក ខេត្តព្រះវិហារ។<br>- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមពិធីប្រកាសដាក់អោយអនុវត្ត នូវនិយាម បណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការពង្រឹងសមាហរណកម្ម យេនឌ័រ ក្នុងវិស័យសុខាភិបាល សណ្ឋាគារ (LBN) ខេត្តកំពង់ចាម។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**<br>- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការការយុត្តិធម៌ បានចូលរួមប្រជុំ ទទួលយកលទ្ធផលទម្រង់សម្ភាសន៍ កំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សទាំង៣ប្រភេទ ដែល គ.ខ.ប.ជ ខេត្តសៀមរាបផ្ញើមក។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ<br>○ បានអញ្ជើញចូលរួមកិច្ចប្រជុំ ពិគ្រោះយោបល់ជាមួយដៃគូសន្ទនា អាស៊ាន និងកាណាដា លើកទី១០ ដឹកនាំដោយ ប្រទេសម៉ាឡេស៊ី តាមប្រព័ន្ធវីដេអូ។<br>○ បានអញ្ជើញចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានលើកទី១៨ ស្តីពីក្រុមការងារឧក្រិដ្ឋឆ្លងដែន ក្នុងកិច្ចការងារប្រឆាំងការជួញដូរមនុស្ស តាមប្រព័ន្ធវីដេអូ។<br>○ បានអញ្ជើញចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី២២ ដឹកនាំដោយ នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា តាមប្រព័ន្ធវីដេអូ។<br>- លោកក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានបើកវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថល ស្តីពីមូលដ្ឋានគ្រឹះនៃការសរសេរកូដកម្មវិធី ដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលជាក្រុមការងារព័ត៌មានវិទ្យាថ្មី នៅសាលប្រជុំ គ.ជ.ប.ជ។ |

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការទេសន្តប្រវេសន៍**<br>- បានចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពជាតិសុខភាពជនទេសន្តប្រវេសន៍ ២០២២-២០៣០ នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>- បានចូលរួមពិធីប្រកាសដាក់អោយអនុវត្ត នូវនិយាម បណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការពង្រឹងសមាហរណកម្ម យេនឌ័រ ក្នុងវិស័យសុខាភិបាល សណ្ឋាគារ (LBN) ខេត្តកំពង់ចាម។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៤ នៃអនុគណៈកម្មការចំពោះកិច្ច អនុវត្តផែនការសកម្មភាពការងារ របស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ.អ.ផ នៅសណ្ឋាគារស៊េរីដង់សុខាភ្នំពេញ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ០៨លើក អ្នកចូលរួមសរុបចំនួន ៣០០នាក់ (ស្រី ១៣៨នាក់)** | |
| **ខេត្តសៀមរាប** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក អ្នកចូលរួមចំនួន ៥២នាក់ ស្រី ២១នាក់។<br>- ប្រជុំក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកពួក ស្វាយលើ ស្រីស្នំ សូទ្រនិគម ចំនួន០៤លើក អ្នកចូលរួមចំនួន ១១២នាក់ ស្រី៤៨នាក់។ |
| **ខេត្តកណ្តាល** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក។<br>- ក្រុមការងារក្រុង ស្រុក-ប្រជុំប្រចាំខែ ចំនួន០៥លើក អ្នកចូលរួមចំនួន១៣៥នាក់ ស្រី៦៩នាក់។ |
| **ខេត្តកំពង់ចាម** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក។ |
| **ខេត្តព្រៃវែង** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក។ |
| **ខេត្តកំពង់ធំ** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន០១លើក។ |